# CAPAA

WASHINGTON STATE COMMISSION ON
ASIAN PACIFIC
AMERICAN AFFAIRS

**គណៈកម្មការរដ្ឋវ៉ាស៊ីនតោនស្តីពីកិច្ចការប្រជាជនអាមេរិក
ដើមកំណើតអាស៊ីប៉ាស៊ីហ្វិក**

ការលើកកម្ពស់ជីវភាពរស់នៅនៃប្រជាជនអាមេរិកកាំង ដើមកំណើតអាស៊ីប៉ាស៊ីហ្វិច

---

**គណៈកម្មការស្តីពីកិច្ចការប្រជាជន
អាមេរិកកាំងដើមកំណើតអាស៊ីប៉ាស៊ីហ្វិច គឺជាទីមន្ត្រីភ្នាក់ងាររបស់
រដ្ឋវ៉ាស៊ីនតោនដែលមាន
គណៈកម្មាការប្រឹក្សាយោបល់មួយដែលមានសមាសភាពសមាជិក
គណៈកម្មាការចំនួន១២រូបដែលតែងតាំងដោយអភិបាល
រដ្ឋវ៉ាស៊ីនតោនដើម្បីធ្វើជាតំណាងឲ្យសហគមន៍ចម្រុះប្រជាជន
អាមេរិកកាំងដើមកំណើតអាស៊ីប៉ាស៊ីហ្វិកក្នុងរដ្ឋវ៉ាស៊ីនតោន។**

---

## តួនាទីរបស់យើង

បេសកកម្មរបស់យើងគឺ ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន អាមេរិកកាំងដើមកំណើតអាស៊ីប៉ាស៊ីហ្វិកនូវក្នុងរដ្ឋវ៉ាស៊ីនតោន។ យើងធ្វើការងារក្នុងភាពជាដៃគូជាមួយសហគមន៍របស់ពួកយើងនិងថ្នាក់ដឹកនាំរដ្ឋ ដើម្បីឆ្លើយតបទៅនឹងក្តីកង្វល់នានានិងធ្វើឲ្យមានការផ្លាស់ប្តូរជាវិជ្ជមាន និងដំណោះស្រាយយូរអង្វែង។ បុគ្គលិកនិងមន្ត្រីគណៈកម្មការរបស់យើង៖

- ធានាថាការបញ្ចេញយោបល់របស់សហគមន៍ទទួលបានការដឹងឮទៅដល់ជួររដ្ឋាភិបាលរបស់រដ្ឋ។
- ផ្តល់ព័ត៌មានដល់សហគមន៍អំពីច្បាប់និងគោលការណ៍ដែលកំពង់អនុវត្តន៍នានាដែលជះឥទ្ធិពលដល់សុខុមាលភាពរបស់ពួកគេ។
- ពង្រឹងផ្លូវច្បាប់ ចំពោះគោលការណ៍ច្បាប់ទាំងឡាយដែលកំពង់អនុវត្តន៍និងសេវាកម្មនានាដែលគាំទ្រដល់តម្រូវការចាំបាច់នានារបស់សហគមន៍។

## ផ្នែកដែលត្រូវយកចិត្តទុកដាក់

- **សិទ្ធិពលរដ្ឋនិងយុត្តិធម៌៖** ពង្រឹងផ្លូវច្បាប់ នូវសមធម៌ជាតិសាសន៍និងសិទ្ធិពលរដ្ឋរួមមានយុត្តិធម៌សម្រាប់ជនអន្តោប្រវេសន៍និងជនភៀសខ្លួនជាដើម។
- **ការអប់រំ៖** អភិវឌ្ឍយុទ្ធសាស្ត្រនានាដើម្បីធានាថា កុមារគ្រប់រូបទទួលបានការអប់រំប្រកបដោយគុណភាពដែលផ្តល់តម្លៃលើពិពិធភាពនិងការគោរពគ្នាទៅវិញទៅមក។
- **សេវាសុខាភិបាលនិងមនុស្សជាតិ៖** លើកកម្ពស់ដំណោះស្រាយនានាដើម្បីពង្រឹងការទទួលបានសេវាសុខភាពនិងសង្គមដែលមានគុណភាពមានតម្លៃសមរម្យ និងសមស្របទៅតាមវប្បធម៌។
- **ការអភិវឌ្ឍសេដ្ឋកិច្ច៖** បង្កើនឱកាសនានាដើម្បីចូលរួមក្នុងភាពជាសហគ្រិនភាពនិងកម្លាំងពលកម្ម។




## មន្ត្រីគណៈកម្មការ

មន្ត្រីគណៈកម្មការបំពេញការងាររយៈពេលបីឆ្នាំក្នុងមួយអាណត្តនិងចូលរួមនៅក្នុងកិច្ចប្រជុំគណៈកម្មការចំនួនប្រាំដងក្នុងមួយឆ្នាំ។ ពួកគេកសាងទំនាក់ទំនងរបស់ពួកគេនៅក្នុងសហគមន៍និងធ្វើការងារដើម្បីស្វែងរកដំណោះស្រាយនានាតាមរយៈការរៀបចំឲ្យមានកិច្ចប្រជុំនៅក្នុងសហគន៍ ជ្រំជ្រែងក្រុមចំរុះ បម្រើការក្នុងគណៈកម្មការដ៏ទៃទៀត ធ្វើការស៊ើបអង្កេតពីវិបត្តិនានានិងផ្តល់ជូនដំបូន្មានដល់អ្នកបង្កើតច្បាប់នានា។

## ប្រវត្តិរបស់យើង

ប្រជាជនអាមេរិកកាំងដើមកំណើតអាស៊ីប៉ាស៊ីហ្វិកធ្លាប់ទទួលនូវការរើសអើងនៅទូទាំងរដ្ឋរបស់យើងនិងក្នុងប្រវត្តិសាស្ត្រនៃប្រជាជាតិយើងហើយបន្តប្រឈមនឹងឧបសគ្គក្នុងការនូវទទួលបានសេវារដ្ឋនានា។ គណៈកម្មការស្តីពីកិច្ចការប្រជាជន អាមេរិកកាំងដើមកំណើតអាស៊ីបាស៊ីហ្វិចត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៧២ ដោយសកម្មជនសហគមន៍ហើយបានដាក់បញ្ចូលទៅក្នុងច្បាប់ដោយរដ្ឋសភានៅឆ្នាំ១៩៧៤ គណៈកម្មការបានបំពេញការងារយ៉ាងខ្លាំងដើម្បីលើកកម្ពស់ការតស៊ូមតិការអប់រំសហគមន៍ការផ្សព្វផ្សាយនិងកិច្ចសហប្រតិបត្តិការនៅក្នុងការជួយគាំទ្រដល់សហគមន៍របស់យើង។

## របៀបចូលរួមដោយវិធីណា

- ជួបជាមួយមន្ត្រីគណៈកម្មការដើម្បីជជែកពីបញ្ហា។
- ចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សានៃគណៈកម្មការ។
- ដាក់ពាក្យសុំបម្រើការជាមន្ត្រីគណៈកម្មការ
- សូមចុះឈ្មោះតាមអ៊ីម៉ែលដើម្បីទទួលព្រឹត្តិប័ត្រព័ត៌មានឬចុចចូលគេហទំព័រដើម្បីមើលព្រឹត្តិប័ត្រព័ត៌មានរបស់យើង។

## សូមទំនាក់ទំនងយើង

CAPAA.WA.GOV

CAPAA@CAPAA.WA.GOV

360.725.5667

FACEBOOK.COM/WACAPAA